# សេវា(កិច្ចបំរើ)ដោយខ្លួនឯងរបស់ Centrelink



We speak your language ☎ 13 1202

*Centrelink Self Service* - **Khmer**

**សូមកត់សំគាល់ថា សេវាដោយខ្លួនឯងមានជាភាសាអង់គ្លេសតែប៉ុណ្ណោះ។ ពុំមានព័ត៌មានលំអិតជាភាសាលោកអ្នកឡើយ។**

## ដើម្បីប្រើសេវាទូរស័ព្ទដោយខ្លួនឯង

1 លើកទូរស័ព្ទ និងចុចលេខ **13 6240***
2 នៅពេលប្រព័ន្ធទូរស័ព្ទសួរសំណួរ សូមនិយាយប្រាប់ **Customer Access Number (CAN)** (**លេខប្រើប្រាស់សំរាប់អតិថិជន**) របស់លោកអ្នក។ និយាយប្រាប់លេខទាំងមូល ដោយមានរួមទាំងអក្សរនៅខាងចុង។
3 ចុចលេខ **Personal Identification Number - PIN** (**លេខអត្តសញ្ញាណផ្ទាល់ខ្លួន**)ប្រាំមួយខ្ទង់របស់លោកអ្នក។
4 ស្តាប់មាតិកាដែលរៀបចំទៅតាមតម្រូវការផ្ទាល់ខ្លួន ហើយនិយាយប្រាប់ឡើងវិញនូវសេវាដែលលោកអ្នកចង់បាន។ បើលោកអ្នកដឹងអំពីអ្វីៗដែលត្រូវនិយាយរួចហើយ លោកអ្នកមិនចាំបាច់រង់ចាំរហូតទាល់តែលោកអ្នកស្តាប់ឮសេវានោះទេ។

## ជំរើសសេវាដោយខ្លួនឯងរបស់លោកអ្នកមានរួមទាំង:

- **ប្រាក់បើកឲ្យជាមុន**—ដាក់ពាក្យសុំ Family Tax Benefit Advance Payment (ប្រាក់បំណាច់ពន្ធដារគ្រួសារបើកឲ្យជាមុន), ឬឆែកមើលថាតើលោកអ្នកអាចទទួលប្រាក់នេះដែរឬទេ (ប្រាក់បើកឲ្យជាមុនតាមប្រភេទផ្សេងទៀត នឹងមាននៅពេលខាងមុខឆាប់ៗនេះ)
- ស្តាប់**ព័ត៌មានអំពីប្រាក់បំណាច់**របស់លោកអ្នក
- **ធ្វើរបាយការណ៍ប្រចាំពេលពីរអាទិត្យ**របស់លោកអ្នក—បើលោកអ្នកត្រូវរាយការណ៍ទៅឲ្យ Centrelink នៅរៀងរាល់ពេលពីរអាទិត្យ
- **គោលបំណងសិក្សា**—បើលោកអ្នកកំពុងសិក្សាពេញពេល លោកអ្នកអាចប្រាប់អំពីគោលបំណងសិក្សានៅថ្ងៃមុខរបស់លោកអ្នក
- ប្រាប់អំពី **Family Income Estimate (ការប៉ាន់ប្រមាណប្រាក់ចំណូលគ្រួសារ)**របស់លោកអ្នក
- ឆែកមើលតុល្យភាពនៃ **Working Credit (ឥណទានការងារ)**
- ឆែកមើលតុល្យភាពនៃ **Income Bank (បណ្តុំប្រាក់ចំណូលរបស់សិស្សដែលទទួលប្រាក់ឧបត្ថម្ភ)**របស់លោកអ្នក (សិស្ស ឬ Australian Apprentices (អ្នកហាត់ធ្វើការអូស្ត្រាលី))
- ធ្វើសំណូមពរ**ឯកសារ**ណាមួយ ឧទាហរណ៍: របាយការណ៍នៃប្រាក់បំណាច់
- ផ្លាស់ប្តូរលេខ **PIN** របស់លោកអ្នក

សេវានេះនឹងណែនាំលោកអ្នកនៅគ្រប់ជំហានទាំងអស់។ សូមនិយាយដូចធម្មតា - លោកអ្នកមិនចាំបាច់និយាយខ្លាំងៗ ឬយឺតៗឡើយ។

- សេវានេះផ្តល់នូវការប្រើប្រាស់បានចំនួន 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយអាទិត្យ
- ទូរស័ព្ទពីគ្រប់ទីកន្លែងទាំងអស់ក្នុងប្រទេសអូស្ត្រាលី ទៅកាន់លេខចាប់ផ្តើមដោយលេខ 13 បង់ថ្លៃចំនួន 25 សេន។ ទូរស័ព្ទចេញពីទូរស័ព្ទចល័ត ទូរស័ព្ទសាធារណៈដែលត្រូវបង់ប្រាក់ អាចត្រូវបង់ថ្លៃតាមអត្រាខ្ពស់ជាងនោះ។

* បើគេតម្រូវឲ្យលោកអ្នករាយការណ៍អំពីប្រាក់ចំណូលរបស់លោកអ្នកនៅរៀងរាល់ពេលពីរអាទិត្យម្តង លោកអ្នកអាចទូរស័ព្ទដោយផ្ទាល់ទៅលេខ **13 3276** ។ លេខទូរស័ព្ទនេះត្រូវបានគេរៀបចំជាក់លាក់សំរាប់អ្នកដែលកំណត់ធ្វើរបាយការណ៍របស់ខ្លួននៅរៀងរាល់ពេលពីរអាទិត្យម្តង។ (សេវានេះមានជាភាសាអង់គ្លេសតែប៉ុណ្ណោះ)

## ដើម្បីប្រើសេវាអ៊ីនធើណិតដោយខ្លួនឯង

1 បើកមើលវ៉ិបសៃ **www.centrelink.gov.au**
2 ចុចកន្លែងតភ្ជាប់ **<online services>**
3 រើសយកគន្លឹះចុច **<Logon>** (មើលក្នុងកូនប្រអប់ <Quick Logon>)
4 វាយបញ្ចូលលេខ **Customer Access Number - CAN (លេខប្រើប្រាស់សំរាប់អតិថិជន)** និងពាក្យសម្ងាត់។
**កំណត់សំគាល់:** បើលោកអ្នកបានទទួលពាក្យសម្ងាត់បណ្តោះអាសន្ននៅពេលលោកអ្នកបានចុះឈ្មោះ ប្រព័ន្ធនេះនឹងសុំឲ្យ



Australian Government

Centrelink giving you options

លោកអ្នកផ្លាស់ពាក្យសម្ងាត់នោះ។ លោកអ្នកគ្រាន់តែធ្វើតាមការណែនាំនៅលើអេក្រង់តែប៉ុណ្ណោះ។

5 លោកអ្នកនឹងមើលឃើញមាតិកាមួយដែលរៀបចំតាមតម្រូវការផ្ទាល់ខ្លួន។ បន្ទាប់មកលោកអ្នកអាចជ្រើសយកជំរើសនានាដែលបំពេញតាមសេចក្តីត្រូវការរបស់លោកអ្នកប្រសើរបំផុត។

6 នៅពេលដែលលោកអ្នកបើកមើលជំរើសដែលលោកអ្នកបានជ្រើសយក ប្រព័ន្ធនេះអាចសុំឲ្យលោកអ្នកបង្កើត“**សំណួរនិងចម្លើយសម្ងាត់**” ខ្លះ។ ទង្វើនេះនឹងជួយការពារព័ត៌មានផ្ទាល់ខ្លួននិងសម្ងាត់របស់លោកអ្នក។

## សេវាអ៊ីនធើរណិតដោយខ្លួនឯង អនុញ្ញាតឲ្យលោកអ្នកធ្វើកិច្ចការទាំងឡាយ ដូចជា:

- ឆែកមើលពេលដែលលោកអ្នកនឹងទទួលប្រាក់ពី Centrelink ឬ Family Assistance Office (ការិយាល័យផ្តល់ជំនួយដល់គ្រួសារ)
- រាយការណ៍នូវប្រាក់ចំណូលពីការងាររបស់លោកអ្នក
- ផ្តល់ព័ត៌មានគ្រាសព្វថ្ងៃនៃ Family Income Estimate (ការប៉ាន់ប្រមាណប្រាក់ចំណូលគ្រួសារ)របស់លោកអ្នក
- ប្រាប់យើងខ្ញុំអំពីផែនការសិក្សារបស់លោកអ្នកនៅថ្ងៃមុខ
- ដាក់ពាក្យសុំ Family Tax Benefit (ប្រាក់បំណាច់ពន្ធដារគ្រួសារ), Austudy ឬ Youth Allowance (ប្រាក់ជំនួយយុវជន)

ដើម្បីទទួលព័ត៌មានបន្ថែមនិងជំនួយ សូមចុចបើកកន្លែងតភ្ជាប់ <online services> នៅក្នុងវិបសៃយើងខ្ញុំ **www.centrelink.gov.au** ទូរស័ព្ទទៅលេខផ្តើមដោយលេខ **13** ជាធម្មតារបស់លោកអ្នក ឬអញ្ជើញទៅកាន់ការិយាល័យ Centrelink ។

ដើម្បីនិយាយទៅកាន់ Centrelink ជាភាសាខ្មែរ សូមទូរស័ព្ទទៅលេខ **13 1202*** ។
លោកអ្នកក៏អាចរកឃើញព័ត៌មានជាភាសាលោកអ្នក នៅតាមវិបសៃ **www.centrelink.gov.au** ផងដែរ។

* *លោកអ្នកអាចប្រើកិច្ចបំរើទូរស័ព្ទស្តង់ដារនៅគ្រប់ទីកន្លែងទាំងអស់ក្នុងរង្វង់ប្រទេសអូស្ត្រាលីដើម្បីទូរស័ព្ទទៅកាន់លេខចាប់ផ្តើមដោយលេខ “13” ដោយបង់ថ្លៃមិនលើសពីថ្លៃទូរស័ព្ទក្នុងតំបន់ឡើយ (ថ្លៃទូរស័ព្ទអាចមានតម្លៃខុសៗគ្នា ដោយអាស្រ័យលើក្រុមហ៊ុនផ្តល់កិច្ចបំរើទូរស័ព្ទ)។ ទូរស័ព្ទទៅលេខចាប់ផ្តើមដោយលេខ “1800” ឥតមានគិតថ្លៃទេ។ ទូរស័ព្ទចេញពីទូរស័ព្ទសាធារណៈដែលត្រូវបង់ប្រាក់ ទូរស័ព្ទចល័ត និងត្រូវបង់ថ្លៃតាមអត្រាខ្ពស់ជាងនោះ។*